# ការវិនិច្ឆ័យសេចក្ដីប្រកបដោយយុត្តិធម៌ (Fair Trial)

ការកាត់សេចក្ដីដោយយុត្តិធម៌ មានកំណើតតាំងពីក្នុង Magna Carta ឆ្នាំ១២១៥។ គេអះអាងថា វាជាវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬរហូតដល់មានឋានៈជា *jus cogens*។

គោលការណ៍ មានចែងនៅក្នុងលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដូចជា ICC មាត្រា៦៧។ មុននេះ សិទ្ធិត្រូវបានចែងក្នុងអនុសញ្ញាសិទ្ធិមនុស្សជាច្រើន ហើយដែលលម្អិតជាងគេគឺ កតិកាសញ្ញាស្ដីពីសិទ្ធិប្រជាពលរដ្ឋក្នុងមាត្រា១៤។ មានសិទ្ធិចំនួនបីប្រភេទ ទាញពីសញ្ញាណនៃសវនាការដោយយុត្តិធម៌៖ ការវិនិច្ឆ័យសេចក្ដីដោយយុត្តិធម៌ ដោយស្មើភាព (គោលការណ៍ adversary) ការធានាជាអប្បបរិមា និងគោលគំនិតទូទៅនៃសវនាការដោយយុត្តិធម៌ មានការធានាដំណើរការត្រឹមត្រូវ (due process)។

ទាញចេញពីនេះ មានគោលការណ៍ចំនួនបី៖ គោលការណ៍សមភាព (equality of arms) គោលការណ៍សាធារណៈនៃសវនាការ (principle of publicity) និងគោលការណ៍ពន្លឿននីតិវិធី (principle of expeditiousness)។

ទោះបីភាគីទាំងអស់ក្នុងនីតិវិធី ត្រូវបានការពារ និងធានាក្ដី ការការពារក្នុងសវនាការប្រកបដោយយុត្តិធម៌ ត្រូវបានគេមើលឃើញថា ជាការធានាសំដៅជាចម្បងដល់ជនត្រូវចោទ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 324-325)។